**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

-----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ [illegible] អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្ដីពីការគ្រប់គ្រងអាកាសយានដ្ឋាន អន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

# **សំរេច**

**ប្រការ ១.-**

ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

- ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម **ព្រំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការរង នៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ អនុប្រធាន
- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- ឯកឧត្តម **ជាន់ ទូន** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ សមាជិក
- ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងទី១នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **មាស គឹមសុវ៉ាវ៉ូ** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ទោ **ស៊ឹង សំណាង** មេបញ្ជាការកងទ័ពជើងអាកាស សមាជិក
- ឯកឧត្តម **ក្រាញ់ តូនី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក
- ឯកឧត្តម **អ៊ុង អឿន** អភិបាលរងទី១ខេត្តសៀមរាប សមាជិក

- ឯកឧត្តម ម៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម សូ ម៉ារ៉ា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ សមាជិក
- លោក ស៊ុត តារា ប្រធាននាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម សមាជិក
- លោក ម៉ុន នី ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក
- លោក ម៉ុន រដ្ឋា ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

**ប្រការ ២.-**

សមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដូចមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចនេះ មានភារកិច្ចអនុវត្តការងារស្របតាមខ្លឹមសារ និងបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងសាមីខ្លួន ដូចមានចែង ក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ១២ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ